# តើការផ្លាស់ប្តូរប្រព័ន្ធដោយគ្មានការអនុញ្ញាតគឺជាអ្វី?

ការផ្លាស់ប្តូរប្រព័ន្ធដោយគ្មានការអនុញ្ញាត គឺនៅពេលដែលសេវាកម្មទូរស័ព្ទប្រើខ្សែរបស់លោកអ្នក ត្រូវបានប្តូរទៅកាន់ក្រុមហ៊ុនមួយផ្សេងទៀតដោយមិនមានការអនុញ្ញាតិរបស់លោកអ្នក។



California Public
Utilities Commission

**Telecommunications Education and Assistance in Multiple-Languages (TEAM) Program**

www.cpuc.ca.gov/team-and-changes

cabteamandchanges@cpuc.ca.gov

If you are not able to resolve your dispute with your service provider, call the Consumer Affairs Branch (800) 649-7570

# ការផ្លាស់ប្តូរប្រព័ន្ធ ដោយគ្មានការអនុញ្ញាត

គណៈកម្មការ

សេវាកម្មសាធារណៈ

ប្រចាំរដ្ឋកាលីហ្វ័រញ៉ា





# ការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត

សូមអានវិក្កយប័ត្រទូរស័ព្ទរបស់លោកអ្នកដោយប្រុងប្រយ័ត្នតាមខែនិមួយៗ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន និងប្រាក់កំរៃ។ ឧទាហរណ៍ ប្រសិនបើសេវាកម្មហៅទូរស័ព្ទចំងាយឆ្ងាយរបស់លោកអ្នក មិនកំពុងត្រូវបានផ្ដល់ជូនដោយក្រុមហ៊ុនដែលលោកអ្នកបានជ្រើសរើសទេ នោះលោកអ្នកត្រូវបានផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាតហើយ។ ប្រសិនបើលោកអ្នកត្រូវបានផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត នោះលោកអ្នកមិនចាំបាច់ត្រូវបង់ប្រាក់សម្រាប់រយៈពេល 30 ថ្ងៃដំបូងនៃសេវាកម្មរបស់ក្រុមហ៊ុនដែលបានផ្លាស់ប្ដូរនោះទេ។ ហើយក៏ត្រូវប្រាប់ក្រុមហ៊ុនទូរស័ព្ទក្នុងតំបន់ដែលមានការអនុញ្ញាតិរបស់លោកអ្នកផងដែរថា លោកអ្នកចង់ឱ្យកំរៃផ្លាស់ប្ដូរប្រព័ន្ធទាំងអស់ (ប្រាក់កំរៃសម្រាប់ការប្ដូរក្រុមហ៊ុន) ដកចេញពីវិក្កយប័ត្ររបស់លោកអ្នក។

លោកអ្នកអាចស្វែងរកក្រុមហ៊ុនហៅទូរស័ព្ទចំងាយឆ្ងាយណាមួយ ដែលកំពុងផ្ដល់សេវាកម្មជូនដល់លោកអ្នក តាមរយៈការហៅទូរស័ព្ទមកកាន់លេខ 1-700-555-4141 ចេញពីទូរស័ព្ទតាមលំនៅដ្ឋានរបស់លោកអ្នក។ ការថតទុកជាសំលេងនឹងប្រាប់លោកអ្នកអំពីឈ្មោះនៃក្រុមហ៊ុនហៅទូរស័ព្ទចំងាយឆ្ងាយបច្ចុប្បន្នរបស់លោកអ្នក។

# បញ្ហាត្រូវដឹងអំពីការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត

## តើត្រូវធ្វើអ្វីខ្លះប្រសិនបើលោកអ្នកត្រូវបានផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត

ប្រសិនបើលោកអ្នកត្រូវបានផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត សូមចាត់វិធានការទាំងនេះដើម្បីទទួលបានសេវាកម្មមកវិញជាមួយក្រុមហ៊ុនដែលលោកអ្នកបានជ្រើសរើសយក និងដើម្បីទទួលបានការកែតម្រូវវិក្កយប័ត្ររបស់លោកអ្នក:

1) សូមទំនាក់ទំនងទៅកាន់ក្រុមហ៊ុនទូរស័ព្ទប្រចាំតំបន់របស់លោកអ្នក ឬក្រុមហ៊ុនហៅទូរស័ព្ទចំងាយឆ្ងាយដែលបានជ្រើសរើសរបស់លោកអ្នក ដើម្បី រាយការណ៍ពីការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត និងត្រូវបានប្ដូរត្រឡប់ទៅកាន់ក្រុមហ៊ុនដែលបានជ្រើសរើសរបស់លោកអ្នក។ សូមច្បាស់ថា លោកអ្នកមិនត្រូវបានគិតកំរៃដែលត្រូវបានប្ដូរត្រឡប់។ លោកអ្នកអាចមានលក្ខណៈសម្បត្តិទទួលបានឥណទានមួយ ដូចនេះសូមសាកសួរអំពីរឿងនេះនៅ ពេលលោកអ្នកហៅទូរស័ព្ទ។

2) សូមរក្សាបញ្ជីអ្នកគ្រប់គ្នាដែលអ្នកធ្លាប់បាននិយាយទៅកាន់អំពីបញ្ហានេះ។ រាយកាលបរិច្ឆេទ ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណរបស់បុគ្គលិក និងអ្វីដែលជនម្នាក់ៗបានយល់ព្រមធ្វើឱ្យលោកអ្នក។

3) ដាក់បណ្ដឹងទៅកាន់គណៈកម្មការសេវាកម្មសាធារណៈប្រចាំរដ្ឋកាលីហ្វ័រញ៉ា (CPUC)។ សូមហៅទូរស័ព្ទមកកាន់លេខ 1 (800) 649-7570 ឬសូមមើល www.calphoneinfo.com។ នេះនឹងជួយការពារអ្នកផ្សេងទៀតពីការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត។

## រារាំងការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត

ដើម្បីរារាំងការផ្លាស់ប្ដូរប្រព័ន្ធដោយគ្មានការអនុញ្ញាត សូមចាត់វិធានការទាំងនេះ:

- មិនត្រូវផ្ដល់ព័ត៌មានផ្ទាល់ខ្លួនតាមរយៈទូរស័ព្ទឱ្យទៅជនចំលែកដែលហៅទូរស័ព្ទរកលោកអ្នក។
- សូមស្នើសុំឱ្យក្រុមហ៊ុនរបស់លោកអ្នកកត់ត្រាអ្នកដែលមានការអនុញ្ញាតិឱ្យធ្វើការផ្លាស់ប្ដូរនៅលើគណនីរបស់លោកអ្នក។
- សូមអានគ្រប់យ៉ាងមុនពេលលោកអ្នកចុះហត្ថលេខា។ ការភ្នាក់ការប្រកួត ឬការពិនិត្យ អាចនាំលោកអ្នកយល់ខុសចំពោះការអនុញ្ញាតឱ្យផ្លាស់ប្ដូរ។
- សូមរាយការណ៍ពីទូរស័ព្ទចល័តដែលបាត់ ឬដែលត្រូវគេលួចទៅកាន់ក្រុមហ៊ុនឥតខ្សែភ្លាមៗ ឱ្យបិទសេវាកម្មរបស់លោកអ្នក អាស្រ័យហេតុនេះ ជននោះមិនអាចប្រើវា និងបង្កើនថ្លៃវិក្កយប័ត្ររបស់លោកអ្នក។
- អ្នកមិនចាំបាចនិយាយទៅកាន់អ្នកផ្សព្វផ្សាយទីផ្សារតាមទូរស័ព្ទនោះទេ។ សូមចុះឈ្មោះទូរស័ព្ទរបស់លោកអ្នកជាមួយការចុះឈ្មោះ "ហាមហៅទូរស័ព្ទ" ដើម្បីជៀសផុតពីការហៅទូរស័ព្ទរបស់អ្នកផ្សព្វផ្សាយទីផ្សារតាមទូរស័ព្ទ។
- ប្រសិនបើលោកអ្នកមិនចង់ផ្លាស់ប្ដូរក្រុមហ៊ុនទេ មិនត្រូវនិយាយយល់ព្រមចំពោះអ្វីដែលអ្នកផ្សព្វផ្សាយទីផ្សារតាមទូរស័ព្ទប្រាប់លោកអ្នកនោះទេ។ ក្រុមហ៊ុននេះអាចព្យាយាមប្រើប្រាស់រឿងនេះជាអំណះអំណាងថា លោកអ្នកបានយល់ព្រមចំពោះការបញ្ជាទិញ។







## តើត្រូវការដាក់បណ្ដឹងឬទេ?

បណ្ដឹងអាចត្រូវបានផ្ញើទៅកាន់:

Slamming Complaints
Consumer Branch Affairs
California Public Utilities Commission
505 Van Ness Avenue
San Francisco, CA 94102

សូមផ្ដល់ជូននូវព័ត៌មានដូចខាងក្រោម: ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ អាសយដ្ឋានអ៊ីម៉ែល *ឈ្មោះរបស់ក្រុមហ៊ុនទាំងអស់ដែលពាក់ព័ន្ធនៅក្នុងបណ្ដឹងរបស់លោកអ្នក របាយការណ៍នៃហេតុការណ៍ ច្បាប់ថតចម្លងនៃវិក្កយប័ត្ររបស់លោកអ្នក អ្វីដែលលោកអ្នកបានបង់ និងអ្វីដែលលោកអ្នកចង់ឱ្យគេសង។*